ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៣៨១

ចុះថ្ងៃទី ២៧-០២-២០០៧

សាលក្រមលេខ ៤៦ " ឆ "

ចុះថ្ងៃទី ០៨-៧ -២០០៩

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងរាជធានីភ្នំពេញនាថ្ងៃទី២៤ **ខែមិថុនា ឆ្នាំ ២០០៩** ដោយមានសមាសភាពចូលរួមដូចតទៅ :

**ចៅក្រមជំនុំជម្រះ**

-លោកស្រី [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨១ ចុះថ្ងៃទី ២៧-០២-២០០៧ ដែលមានជនជាប់ចោទ :**

ឈ្មោះ[redacted]អាយុ៣៨ឆ្នាំ ភេទប្រុស ជាតិខ្មែរ កើតនៅភូមិអណ្តូង ឃុំគោករកា ស្រុកដង្កោ ខេត្តកណ្តាល ទីលំនៅសព្វថ្ងៃភូមិអូរអណ្តូង សង្កាត់គោករកា ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ[redacted] ឪពុកឈ្មោះ[redacted] "ស្លាប់" ម្តាយឈ្មោះ[redacted] "រស់" ទោសពីមុនគ្មាន ។

ត្រូវចាប់ខ្លួនថ្ងៃទី ១០-១២-២០០៨ ឃុំខ្លួនលេខ២១៦៨តព្រ ចុះថ្ងៃទី ១៨-១២-២០០៨

ជាប់ចោទពីបទ: **ផ្តល់សក្ខីភាពក្លែង និង ក្លែងលិខិតឯកជន** ប្រព្រឹត្តនៅ ក្រុងភ្នំពេញ កាលពីថ្ងៃទី ០៤ខែ មករា ឆ្នាំ២០០៤ ។

-ដើមរដ្ឋប្បវេណីឈ្មោះ[redacted] ភេទប្រុស អាយុ៦០ឆ្នាំ ទីលំនៅសព្វថ្ងៃផ្ទះលេខ១២៤ ផ្លូវលេខ ១០១៩ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ដែលមានលោក[redacted]ជាមេធាវីតំណាង

-មេធាវីការពារអោយជនជាប់ចោទគឺលោក[redacted]

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ :**

នៅថ្ងៃទី ១០-០៣-១៩៩៣ ថ្ងៃទី ១០-០៤-១៩៩៣ និងថ្ងៃទី០៤-១០-២០០៤ ឈ្មោះ[redacted]បានធ្វើសកម្មភាពជាមួយពួកគេក្លែងលិខិតកិច្ចសន្យាទិញលក់ដី និង ស្នាមមេដៃ ដោយដាក់ឈ្មោះ [redacted]ជាបានលក់ដីដែលស្ថិតនៅភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ មកអោយរូបខ្លួនឈ្មោះ [redacted] រួចយកលិខិតក្លែងនោះទៅប្តឹងទៅតុលាការក្រុងភ្នំពេញ ដើម្បីឱ្យតុលាការសំរេចប្រគល់ដីមកខ្លួនធ្វើជាម្ចាស់កម្មសិទ្ធស្របច្បាប់ ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ៦៦៧អយជ ចុះថ្ងៃទី៣១-៣-២០០៩ របស់តំណាងអយ្យការអមតុលាការដំបូងរាជធានីភ្នំពេញ ។



Scanned by CamScanner

បានឃើញដីការបញ្ជូនរឿងទៅជំនុំជំរះលេខ ៧២៦៩ ត-ព្រ ចុះថ្ងៃទី ២១-៩-២០០៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

## ពេលសវនាការ

ជនជាប់ចោទឈ្មោះ[redacted]ឆ្លើយថា: ខ្ញុំពិតជាបានផ្តល់សក្ខីភាពក្លែងប្រាកដមែន ខ្ញុំមិនស្គាល់[redacted]ទ ខ្ញុំបានទទួលលិខិតពីលោក[redacted]ជាអ្នកធ្វើឯកសារ[redacted]មិនបានរកស៊ីជាមួយខ្ញុំបានទេ ក្រោយពីបានសាលក្រម ហើយខ្ញុំបានពឹងអោយឈ្មោះ[redacted]កទៅបញ្ជូ[redacted]កស៊ីជាមួយខ្ញុំ កិច្ចសន្យាចុះថ្ងៃទី .១០-៣-១៩៩៣ និង ចុះថ្ងៃទី១០-៤-១៩៩៣ ខ្ញុំពុំបានផ្តិតមេដៃនៅចំពោះមុ[redacted]ទេ ខ្ញុំជាអ្នកយកឯកសារអោយតុលាការ រួចតុលាការកោះហៅអ្នកណាមកសួរខ្ញុំមិនដឹងហើយក៏មិនបានអោយគេទៅឆ្លើយដែរ ខ្ញុំឈរឈ្មោះទិញដីដោយឈ្មោះ **ឯក អេង** (នគរបាលប៉ុស្តិ៍) ជាអ្នកធ្វើឯកសារឱ្យខ្ញុំ ។ ប្រាក់ខ្ញុំយកអោយ[redacted] ហើយ[redacted]អោយអ្នកលក់បន្តទៀត ដោយក្នុង តលៃ១ម៉ែ=១ដុល្លា ដីនោះសរុបលុយអស់ជាង ១០ម៉ឺនដុល្លា(ដប់ម៉ឺនដុល្លារអាមេរិច) ។ ឯកសារខ្ញុំជាអ្នកយកផ្តល់អោយតុលាការ ហើយតុលាការសំរេចសេចក្តីអោយខ្ញុំឈ្នះ គោលបំណងដើម្បីទៅធ្វើបណ្ណ័កាន់កាប់បណ្ណ័ឈ្មោះ[redacted]ខ្ញុំជាអ្នកយកមកដាក់នៅតុលាការ ជាបណ្ណ័ថតចំលង ឯកសារដើមពុំដឹងនៅទីណាទេ ។

មេធាវីតំណាងដើមបណ្តឹង[redacted]សន្និដ្ឋាន :នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨១ ចុះថ្ងៃទី ២៧-០២-២០០៧ បានបញ្ជាក់ថាជនជាប់ចោទ និង ពួកគេបានយកឈ្មោះកូនក្តីខ្ញុំបាទទៅធ្វើជាសាក្សីក្នុងរឿងរដ្ឋប្បវេណីលេខ ២២៨ ចុះថ្ងៃទី ០២-០៣-២០០៤ ដោយយកឈ្មោះកូនក្តីខ្ញុំ[redacted]ធ្វើជាអ្នកលក់ដីអោយឈ្មោះ[redacted]តែតាមការពិតកូនក្តីខ្ញុំបាទឈ្មោះ[redacted]ប្រាកដមិនដែលបានលក់ដីអោ[redacted]ឡើយ ហើយក៏មិនដែលបានចូលទៅបំភ្លឺនៅតុលាការពីរឿងលក់ដីអោយ សុខ យិន ដែរ ។ ក្នុងរឿងក្លែងអត្តសញ្ញាណកូនក្តីខ្ញុំបាទឈ្មោ[redacted]គឺពុំមែនមានតែ សុខ យិន ម្នាក់ទេគឺមានអ្នករៀបចំឯកសារ និង មានអ្នកផ្តល់ថវិកាដើម្បីបានសំរេចនូវគោលបំណងយកដីទៅចាត់ចែងជាកម្មសិទ្ធិ និង លក់បន្តទៀតនោះ ហើយពួកគេដែលបានប្រព្រឹត្តជាមួយ[redacted]ចៅក្រមស៊ើបសួរបានលើកលែងចោទប្រកាន់ដោយគ្មានសាវតាជាតិ ប៉ុន្តែតាមពិតពួកគេសុទ្ធតែមានសាវតាជាតិទាំងអស់ ដូចនេះខ្ញុំបាទនៅតែទទូចសុំអោយតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និង សុំអោយបង្វិលសំណុំរឿងដើម្បីចោទប្រកាន់លើពួកគេតាមច្បាប់ ។

តំណាងអយ្យការសន្និដ្ឋាន[redacted]ទួលស្គាល់ថាបានធ្វើកិច្ចសន្យាទិញដី និង កិច្ចសន្យាប្រគល់ប្រាក់[redacted] ពិតមិនបានចូលរួមក្នុងលិខិតនេះឡើយ អំពើរបស់ឈ្មោ[redacted]គឺជាបទល្មើសដូចក្នុងមាត្រា៥០.៥៦នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ឯការបរិច្ចេទអោយតុលាការយកថ្ងៃបង្ហាញថ្ងៃពេលសវនាការ ដូចនេះតុលាការសុំតំកល់ការចោទប្រកាន់ទុកជាបានការដដែល ។

មេធាវីជនជាប់ចោទសន្និដ្ឋានការពារ : ខ្ញុំយល់ថាកូនក្តីខ្ញុំធ្វើតាមគេជាអ្នកធ្វើអោយ ដោយឈ្មោ[redacted]ជាអ្នកធ្វើឱ្យ តែកូនក្តីខ្ញុំដោយរៀនបានកំរិតវប្បធម៌តិចពេកក៏មិនបានពិចារណាវែងឆ្ងាយទើបគាត់ធ្វើដូចនេះ សូមលោកប្រធានចៅក្រមជំនុំជំរះមេត្តាជួយបន្ធូរបន្ថយទោសឱ្យកូនក្តីខ្ញុំបាទដោយក្តីអនុគ្រោះ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីតំណាងដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ



Scanned by CamScanner

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យ និង ពិចារណាលើសំណុំរឿងសព្វគ្រប់

## សាលាដំបូងរាជធានីភ្នំពេញ

## យល់ឃើញថា៖

-តាមកំណត់ហេតុយកចម្លើយឈ្មោះ[redacted]នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ២២៨ ចុះថ្ងៃទី០២-៣-២០០៤ ជាបុគ្គលក្លែងបន្លំដាក់ឈ្មោះ[redacted]គឺចុះថ្ងៃទី២៨-០៤-២០០៤ ដែលកាលបរិច្ឆេទនេះជាពេលវេលាធ្វើអោយតុលាការជឿជាក់ ឯកាលបរិច្ឆេទចុះថ្ងៃទី ០៤-១០-២០០៤ គឺជាពេលវេលាសាលក្រមចូលជាស្ថាពរហើយតំណាងអយ្យការមានការភ័ន្តច្រឡំលើកាលបរិច្ឆេទនេះ ដូចនេះដើម្បីចោទប្រកាន់ជនជាប់ចោទ អោយត្រូវតាមកាលបរិច្ឆេទនៃការផ្តល់សក្ខីភាពក្លែងក្លាយ តុលាការត្រូវកែប្រែកាលបរិច្ឆេទនៃការចោទប្រកាន់ពីថ្ងៃទី០៤-១០-២០០៤ មកជាថ្ងៃទី២៨-០៤-២០០៤វិញ ។

-កាលពីថ្ងៃទី ២៨- ០៤-២០០៤ ,១០-០៣-១៩៩៣ ,១០-០៤-១៩៩៣ មានអំពើផ្តល់សក្ខីក្លែងក្លាយ និងក្លែងលិខិតឯកជនមួយកើតឡើងនៅក្រុងភ្នំពេញ ដែលអំពើនេះបង្កឡើងដោយឈ្មោះ[redacted]

-ជនជាប់ចោទបានឱ្យមនុស្សម្នាក់ដាក់ឈ្មោះថា[redacted] ដើម្បីប្តឹងតុលាការក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ២២៨ ចុះថ្ងៃទី០២-០៣-២០០៤ ថាបានលក់ដីស្ថិតនៅក្នុងភូមិចាំយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ មកឱ្យខ្លួនហើយ ដោយសារតែតុលាការជឿលើសាក្សីឈ្មោះនេះ ទើបតុលាការសំរេចប្រគល់ដីនេះអោយឈ្មោះ[redacted]តាមសាលក្រមរដ្ឋប្បវេណី ១៤ឃ ចុះថ្ងៃទី១៩-០៥-២០០៤ ប៉ុន្តែឈ្មោះ[redacted]នេះគឺជាមនុស្សក្លែងក្លាយ ព្រោះតាមប្រវត្តិរូបបញ្ជាក់ថា ឪពុកម្តាយប្រពន្ធកូនវាខុសពីប្រវត្តិរូប[redacted]ដើមបណ្តឹងក្នុងរឿងព្រហ្មទណ្ឌលេខ៣៨១ ចុះថ្ងៃទី ២៧-០២-២០០៧ ។

-អំពើរបស់ជនជាប់ចោទ[redacted]គឺជាការបង្ហាញនូវសក្ខីភាពក្លែងក្លាយក្នុងនីតិវិធីតុលាការ ហើយអំពើនេះជាបទធ្វើសក្ខីភាពក្លែងក្លាយ តាមមាត្រា៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-តាមកិច្ចសន្យាទិញ និង លក់ដី ចុះថ្ងៃទី ១០-០៣-១៩៩៣ និង លិខិតប្រគល់ប្រាក់ផ្តាច់ចុះថ្ងៃទី ១០-០៤-១៩៩៣ បានបង្ហាញថាឈ្មោះ [redacted]ជាអ្នកលក់ដី និងជាអ្នកទទួលប្រាក់ ប៉ុន្តែការប្តឹងរបស់ដើមបណ្តឹងឈ្មោះ[redacted] បញ្ជាក់ថាខ្លួនមិនដែលផ្តិតមេដៃលក់ដី និងទទួលប្រាក់ពីឈ្មោះ សុខ យិន ឡើយ នេះបញ្ជាក់ថាលិខិតស្នាមដែលឈ្មោះ[redacted] ធ្វើឡើងនេះគឺជាឯកសារក្លែងក្លាយទាំងអស់ ។

-អំពើរបស់ជនជាប់ចោទគឺជាការក្លែងឯកសារឯកជន ដែលអំពើនេះត្រូវចាត់ជាបទព្រហ្មទណ្ឌតាមមាត្រា៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-លិខិតប្រគល់ប្រាក់ផ្តាច់ចុះថ្ងៃទី ១០-០៤-១៩៩៣ រវាងឈ្មោះ[redacted]និងឈ្មោះ[redacted]និងកិច្ចសន្យាទិញ និងលក់ដី ចុះថ្ងៃទី ១០-០៣-១៩៩៣ រវាងអ្នកលក់[redacted] និង អ្នកទិញឈ្មោះ[redacted]គឺជាឯកសារក្លែងក្លាយ វាពុំមានតំលៃគតិយុត្តិឡើយ ។

-តាមចម្លើយរបស់ជនជាប់ចោទថាលិខិតប្រគល់ប្រាក់ចុះថ្ងៃទី ១០-០៤-១៩៩៣ និង កិច្ចសន្យាទិញលក់ដីចុះថ្ងៃទី ១០-០៣-១៩៩៣ រវាងខ្លួន និង ឈ្មោះ[redacted]គឺឈ្មោះ[redacted]ជាប្រធានប៉ុស្តិ៍នគរបាលជាអ្នករៀបចំអោយនោះតុលាការពុំអាចជឿបានឡើយ ព្រោះថាពុំមានសាក្សី និងឯកសារបញ្ជាក់ជូនតុលាការឡើយ ម្យ៉ាងខ្លួនជាអ្នកប្រគល់ប្រាក់ថ្លៃដី ហេតុអ្វីមិនអោយអ្នកលក់ដីមកផ្តិតមេដៃទទួលប្រាក់ចំពោះមុខខ្លួនទោះ ចំលើយនេះពុំមានលក្ខណៈសមស្របអាចអោយតុលាការជឿបានទេ ។



Scanned by CamScanner

-មានពិរុទ្ធភាព និង ភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាជនជាប់ចោទឈ្មោ[redacted]ភេទប្រុស អាយុ ៣៨ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើផ្តល់សក្ខីភាពក្លែង និង ក្លែងលិខិតឯកជននៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៨-៤-២០០៤ .១៩-៥-២០០៤. ១០-៣-១៩៩៣ . ១០-៤-១៩៩៣ ប្រាកដមែន ។

-លោកមេធាវី[redacted]មេធាវីតំណាងអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]បានប្តឹងសុំទាមទារថ្លៃខូចខាត និង ជំងឺចិត្តចំនួន ៥០.០០០ដុល្លារ( ប្រាំម៉ឺនដុល្លាអាមេរិច) មានលក្ខណៈសមស្របគប្បីតុលាការពិនិត្យ និងសំរេចតាមភាព ជាក់ស្តែង ។

-ដើម្បីចៀសវាងការឃុំខ្លួនហួសនីតិវិធី តុលាការគប្បីផ្តន្ទាទោសជនជាប់ចោទនាពេលនេះ ឯតួកនតុលាការគប្បីបង្វិលសំណុំរឿងជូនលោកព្រះរាជអាជ្ញាវិញ ដើម្បីធ្វើការចោទប្រកាន់ និង ចាត់ការតាមនីតិវិធីជាបន្តទៀត ។

-តាមការផ្តល់ភស្តុតាង និង ការអះអាងរបស់មេធាវីតំណាងដើមបណ្តឹងបញ្ជាក់ថា តួកនមានសាវតាច្បាស់លាស់ ហើយតួកននេះជាអ្នករៀបចំឯកសារក្លែង ហើយជាអ្នកផ្តល់ឯកសារបណ្ណកម្មសិទ្ធិផតចំលងផងដែរ ដែលការអះអាងនេះអាចអោយតុលាការជឿបាន ព្រោះថាជនជាប់ចោទពុំបានឆ្លើយបញ្ជាក់ជូនតុលាការនាពេលសវនាការថាអ្នកណាជាអ្នកផ្តល់បណ្ណកម្មសិទ្ធិអោយមកខ្លួនបានឡើយ ដែលនេះសបញ្ជាក់ថាអ្នកផ្តល់បណ្ណកម្មសិទ្ធិដើម្បីអោយតុលាការសំរេចបដិសេធនោះគឺជាតួកន ហើយតួកននេះតំណាងអយ្យការនៅពុំទាន់បានធ្វើការចោទប្រកាន់ និង បញ្ជូនមកតុលាការជំនុំជំរះឡើយ ដូចនេះដើម្បីកុំអោយជនប្រព្រឹត្តបទល្មើសរួចផុតពីការផ្តន្ទាទោស តុលាការគប្បីបង្វិលសំណុំរឿងទៅអយ្យការវិញ ដើម្បីធ្វើការចោទប្រកាន់លើតួកន និង ចាត់ការតាមនីតិវិធីជាបន្តទៀត ។

## ហេតុដូច្នេះសាលាដំបូងរាជធានីភ្នំពេញ

## វិនិច្ឆ័យសេចក្តី

សរុប

១-ផ្តន្ទាទោសឈ្មោះ[redacted]ភេទប្រុស អាយុ៣៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០៤ឆ្នាំ "បួនឆ្នាំ" គិតបន្តពីសាលក្រមមុន និង ពិន័យជាប្រាក់ចំនួន ៤.០០០.០០០រៀល( បួនលានរៀល)សំរាប់ដាក់ចូលក្នុងថវិការដ្ឋ ពីបទ:ផ្តល់សក្ខីភាពក្លែង និង ក្លែង **លិខិតឯកជន** ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៨-០៤-២០០៤ .១៩-០៥-២០០៤ .១០-០៣-១៩៩៣ និង១០-០៤-១៩៩៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥៦ .៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-បង្គាប់អោយឈ្មោ[redacted]សងថ្លៃខូចខាត និង ជំងឺចិត្តចំនួន ៤០.០០០.០០០រៀល( សែសិបលានរៀល) ឱ្យទៅឈ្មោ[redacted]ដែលមានលោក[redacted]មេធាវីតំណាង ។ ការសុំលើសពីនេះត្រូវច្រានចោល ។

**៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៣៨១ចុះថ្ងៃទី២៧-០២-២០០៧ ទៅព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញវិញ ដើម្បីបើកការស៊ើបសួរលើតួកន និង ចាត់ការតាមនីតិវិធី ។**

៤-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី២៤-០៦-២០០៩ និង ប្រកាសជាសាធារណៈនៅថ្ងៃទី០៨-០៧-២០០៩ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និង ត្រា[redacted]

**ចៅក្រមជំនុំជំរះ**

ហត្ថលេខា និង ត្រា[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ,ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៩

**ក្រឡាបញ្ជី**

**បានឃើញ**

**ចៅក្រមជំនុំជំរះ**

[redacted]



[redacted]

Scanned by CamScanner